# សេចក្តីប្រកាសអញ្ជើញ៖ ការចុះឈ្មោះចូលរួមវគ្គបណ្តុះបណ្តាល ដើម្បីទទួលបានឱកាសបន្តក្នុងការជ្រើសរើសចូលរួមក្នុងការប្រកួតប្រជែង ការពិភាក្សាដេញដោល ស្តីពីអំពើហិង្សាលើស្ត្រី

## អំពីកម្មវិធី

NGO-CEDAW មានកិត្តិយសសូមអញ្ជើញនិស្សិតតាមបណ្តារសកលវិទ្យាល័យនានា អញ្ជើញចុះឈ្មោះចូលរួមវគ្គបណ្តុះបណ្តាល និងការប្រលងប្រជែងពិភាក្សាដេញដោលទាក់ទងនឹងអំពើហិង្សាលើស្ត្រី។ កម្មវិធីនេះនឹងរៀបចំឡើងដោយអធ្យាក្រិត្យនយោបាយ និងមានការអញ្ជើញមន្ត្រីរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិពាក់ព័ន្ធ និងតារាប្រជាប្រិយជាគណៈកម្មាការវាយតំលៃ និងវាឃ្មិនកិត្តិយសផងដែរ ។ កម្មវិធីនេះរៀបចំឡើងក្រោមការឧបត្ថម្ភពីសហគមន៍អ៊ឺរ៉ុប ជំនួយ ផ្តួចផ្តើមក្នុងស្រុកពីរដ្ឋាភិបាលកាណាដាតាមរយៈស្ថានទូតកាណាដា ស្ថានទូតចក្រភពអង់គ្លេស និងព្រះវិហារដាណឺម៉ាក ។

## តើធ្វើដូចម្តេចដើម្បីអាចចូលរួមក្នុងការប្រកួតប្រជែងការពិភាក្សាដេញដោលនេះបាន?

- និស្សិតទាំងអស់ត្រូវបំពេញពាក្យចូលរួមវគ្គបណ្តុះបណ្តាលដែលមានរយៈពេល ១ថ្ងៃជាមុនសិន ។ វគ្គបណ្តុះបណ្តាលនេះនឹងធ្វើឡើងនៅថ្ងៃ **អាទិត្យ ទី២១ ខែតុលា ឆ្នាំ២០១៨** ។ សិក្ខាកាម នឹងបានរៀនសូត្រពីគោលការណ៍គ្រឹះនៃអនុសញ្ញាស៊ីដ សមភាពយេនឌ័រ និង អំពើហិង្សាលើស្ត្រី ពីអ្នកជំនាញការផ្នែកយេនឌ័រ ។
- មានតែបេក្ខជនចំនួន ៦ នាក់តែប៉ុណ្ណោះដែលនឹងត្រូវបានជ្រើសរើសក្នុងកំឡុងពេលនៃវគ្គបណ្តុះបណ្តាល ដើម្បីចូលរួមប្រកួតប្រជែងការពិភាក្សាដេញដោលនាថ្ងៃ **អាទិត្យទី ២ ខែធ្នូ ឆ្នាំ ២០១៨** ។

## តើបេក្ខជនដែលមានចំណាប់អារម្មណ៍ត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

១. មានសញ្ជាតិខ្មែរ

២. អាយុចាប់ពី១៧ ឆ្នាំឡើង

៣. ជានិស្សិតដែលកំពុងសិក្សានៅតាមសកលវិទ្យាល័យនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា

៤. មានចំណាប់អារម្មណ៍ចំពោះសមភាពយេនឌ័រ និងបញ្ហាសិទ្ធិស្ត្រី

៥.មានពេលវេលាគ្រប់គ្រាន់សម្រាប់ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល ១ថ្ងៃ និង/ឬចូលរួមប្រកួតប្រជែងការពិភាក្សាដេញដោលតាមថ្ងៃកំណត់ខាងលើដោយមិនមានការផ្លាស់ប្តូរ ។

## និសិត្សដែលមានចំណាប់អារម្មណ៍ត្រូវដាក់ពាក្យយ៉ាងដូចម្តេច?

និស្សិតដែលមានចំណាប់អារម្មណ៍សូមបំពេញព័ត៌មាននៅក្នុងទម្រង់ចុះឈ្មោះដែលមានភ្ជាប់មកជាមួយ ឬអាចទាញយកពីគេហទំព័រ www.ngocedaw.org រួចផ្ញើរមកកាន់ការិយាល័យអង្គការ NGO-CEDAW ដែលមានអាសយដ្ឋាន ផ្ទះលេខ១៦ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានី ភ្នំពេញ ឬតាមរយៈអ៊ីម៉ែលៈ ngocedaw.pnh@gmail.com អោយបានមុន**ម៉ោង ៥ រសៀល ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៨** ដោយបញ្ជាក់នៅក្នុងកម្មវត្ថុ ថា " *ពាក្យសុំចូលរួមកម្មវិធីប្រកួតប្រជែងការពិភាក្សាដេញដោល ឆ្នាំ ២០១៨*"។

សម្រាប់ព័ត៌មានលំអិតសូមទូរស័ព្ទមកលេខ ០៩២ ៩៤៦ ៤៣៨/ ០១៦ ៣០៩ ២៨២។

***បញ្ជាក់៖ ការចុះឈ្មោះចូលរួមក្នុងកម្មវិធីនេះ និងមិនមានការតម្រូវអោយបង់ថ្លៃអ្វីទាំងអស់ ។***